# ជីវិត និងស្នាដៃរួមគ្នារបស់កសិករ

## តួនាទី និងភារកិច្ចរបស់អាជ្ញាធរមូលដ្ឋាន

## ក្នុងការជួយអភិវឌ្ឍន៍មូលដ្ឋាន



កាលពីថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩ ខ្ញុំបាទបានចូលរួមជជែកពិភាក្សា និងពិគ្រោះយោបល់ទាក់ទងការងារសន្សំប្រាក់ជាមួយប្រជាជននិងប្រធានភូមិ នៅភូមិបុសលាវលើ ឃុំបុសលាវ ស្រុកចិត្របុរី ខេត្តក្រចេះ ដោយសំរាក១យប់នៅក្នុងភូមិដែលមានអ្នកចូលរួមចំនួន ១៩នាក់ ។ តាមរយៈការពិភាក្សាបានឱ្យដឹងថា នៅក្នុងភូមិខាងលើមាន ប្រជាជនរស់នៅចំនួន ១៩៨គ្រួសារ ចំនួនមនុស្សសរុប ៩៦២នាក់ ។ ប្រជាកសិករភាគច្រើនប្រកបមុខរបរធ្វើស្រែ ដាំស្វាយ ពោត ល្ង អំពៅ និងរកត្រីសម្រាប់ចិញ្ចឹមជីវិត ។ កសិករ ចូលរួមបានបញ្ជាក់ថា សព្វថ្ងៃនៅភូមិគាត់មានស្ថាប័ន មីក្រូហិរញ្ញវត្ថុចំនួន ៥ មានប្រជាជនដែលរស់ក្នុងភូមិ ប្រមាណ ៥៨គ្រួសារ បានខ្ចីលុយពីស្ថាប័នទាំងនោះសរុបទឹកប្រាក់ដែលជំពាក់គេប្រមាណជាង ៨០,០០០,០០០ រៀល ដែលការប្រាក់ក្នុង១ខែៗ ផ្តល់ឱ្យស្ថាប័នមីក្រូហិរញ្ញវត្ថុប្រមាណ ២,៥២០,០០០ រៀល ។

ដោយផ្តើមចេញពីការសន្សំប្រាក់ដើម្បីភាពអាស្រ័យលើខ្លួនឯងកសិករនៅក្នុងភូមិបានចាប់ផ្តើមបង្កើតជាក្រុមសន្សំប្រាក់ចំនួន ១០គ្រួសារដោយសន្សំថវិកាផ្ទាល់ខ្លួនដំបូងបានចំនួន ១៦,០០០រៀល ផ្តើមនៅ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៨ ។

គិតត្រឹមដើមខែសីហា ឆ្នាំ២០០៩ នេះក្រុមសន្សំប្រាក់មានអាយុជិត ៨ខែ ហើយនៅភូមិនេះមានសមាជិក សន្សំចំនួន៣៣គ្រួសារ មាន២ក្រុមសន្សំ ដែលមានទឹកប្រាក់សរុប ៥,៣៤០,០០០ រៀល (សូមបញ្ជាក់ថា នៅក្នុងភូមិមានសហគមន៍អភិវឌ្ឍន៍កសិកម្មដែលគាំទ្រដោយមន្ទីរកសិកម្មខេត្តក្រចេះ ដែលមានសមាជិកសរុប ៣៥គ្រួសារ មានទឹកប្រាក់សន្សំសរុប ២,០០០,០០០រៀល ចំនួនសមាជិក និងទឹកប្រាក់ខាងលើមិនរាប់បញ្ចូលសហគមន៍នេះទេ) ។ តាមរយៈការពិភាក្សាគ្នាអ្នកចូលរួមទាំងអស់ ចង់ឃើញភូមិគាត់មានអ្នកភូមិយ៉ាងតិច ៨០ ភាគរយ ចូលរួមក្នុងក្រុមសន្សំប្រាក់ ហើយដែលសមាជិក ក្នុង ១គ្រួសារ ៗ មានប្រាក់សន្សំ ៤,០០០,០០០រៀល នៅក្នុងក្រុមសន្សំប្រាក់រយៈពេល ៥ឆ្នាំខាងមុខ ។ ពួកគាត់បន្ថែមថា ទឹកប្រាក់ដែលយើងសន្សំបានអាចជួយគ្នាយើងបានក្នុង

ភូមិហើយធ្វើឱ្យយើងមានភាពរីកចម្រើន កាលណាយើងមានប្រាក់ច្រើន យើងសប្បាយចិត្តហើយ យើងអាចពង្រីកមុខរបរ ឱ្យកាន់តែប្រសើរថែមទៀតជាពិសេសយើងចង់ឱ្យអ្នកភូមិយើង ខ្ចីលុយក្នុងក្រុមសន្សំយើង។

តើកន្លងមក អាជ្ញាធរមូលដ្ឋានបានចូលរួមអ្វីខ្លះ ទើបធ្វើឱ្យភូមិគាត់មានភាពរីកចម្រើនបាន ប៉ុណ្ណេះ ? តាមរយៈការបញ្ជាក់ពីលោកពូ **ហ៊ីម ខៃ** ជាប្រធានភូមិបុសលាវលើ ដែលមាន អាយុ ៥២ឆ្នាំគាត់បានរៀបរាប់ថា :

- គាត់ធ្វើជាប្រធានភូមិចាប់តាំងពីឆ្នាំ ២០០៦ ។ ក្រោយពីការបណ្ដុះបណ្ដាលពីផលប្រយោជន៍ នៃការសន្សំប្រាក់ដើម្បីភាពអាស្រ័យលើខ្លួនឯង ខ្លួនគាត់ផ្ទាល់បានយកគំនិតទាំងនេះមកធ្វើការ ពិចារណាថា តើវាមានសារៈប្រយោជន៍ និងពិតជាជួយកសិករឬទេ ? ដោយធ្វើការពិចារណា ជាយូរមកគាត់គិតថា ការសន្សំនេះមានប្រយោជន៍ណាស់ គឺពិតជាជួយដល់កសិករ យើងមែន បន្ទាប់មកគាត់ក៏ចាប់ផ្ដើមធ្វើការជួបប្រជុំជាមួយកសិករក្នុងភូមិ ដើម្បីពិភាក្សា និងពិគ្រោះ យោបល់។
- ខ្លួនគាត់ផ្ទាល់បានដាក់ប្រាក់សន្សំដំបូងចំនួន ២០,០០០ រៀល មកដល់ពេលនេះទឹកប្រាក់គាត់ សន្សំសរុបបានចំនួន ២២០,០០០ រៀល ។ ដើម្បីឱ្យប្រជាជនគាត់ជឿជាក់ គាត់បានជួយ និង សហការជាមួយគណៈកម្មការក្រុមសន្សំ បង្កើតបានក្រុមសន្សំចំនួន ២ក្រុម ដែលគាត់មាន ដាក់ទុនសន្សំទាំង ២ក្រុម។
- គាត់បានចំណាយពេលយ៉ាងច្រើនក្នុងការផ្សព្វផ្សាយ និងអប់រំប្រជាជនភូមិគាត់ ដោយជួបមួយ នាក់ ពន្យល់មួយនាក់ ជួបពីរនាក់ ពន្យល់ពីរនាក់ ។ ការដើរជួប និងពន្យល់ជាបុគ្គលមាន ប្រសិទ្ធិភាពណាស់ ជាពិសេសគាត់មានឱកាសឆ្លើយនូវសំណួរ ដែលកសិករនៅសង្ស័យ និង មិនទាន់ច្បាស់។
- គាត់បានចូលរួមប្រជុំ និងដាក់លុយសន្សំយ៉ាងទៀងទាត់ ទោះបីគាត់រវល់ក្ដីយ៉ាងហោចណាស់ គាត់បានប្រាប់ដល់គណៈកម្មការ និងបានផ្ញើលុយមកក្រុមសន្សំផងដែរ ។ ការចូលរួមប្រជុំធ្វើ ឱ្យគាត់មានឱកាសពន្យល់ដល់ប្រជាជនបន្ថែម និងជួយលើកកម្លាំងចិត្តដល់ប្រជាជនផងដែរ ក្នុង នាមអាជ្ញាធរភូមិ ដែលទោះបីគាត់មិនស្ថិតនៅក្នុងគណៈកម្មការក្រុមសន្សំក្ដី ។
- ជារៀងរាល់សប្ដាហ៍ ព្រឹកថ្ងៃព្រហស្បត្តិ៍គាត់បានជួបប្រជុំជាមួយក្រុមប្រឹក្សាឃុំ និងបានជួប ជាមួយប្រធានភូមិនៅភូមិផ្សេងៗ។ គាត់បញ្ជាក់ថាជាឱកាសល្អមួយ សម្រាប់គាត់ក្នុងការ

រាយការណ៍ នូវភាពរីកចម្រើនរបស់ភូមិរបស់គាត់ និងការសន្សំប្រាក់របស់ប្រជាជនដល់ក្រុមប្រឹក្សាឃុំ ហើយឲ្យក្រុមប្រឹក្សា និងប្រធានភូមិផ្សេងៗទៀតជួយជម្រុញ និងពង្រឹងដល់កសិករផ្សេងៗបន្ថែមទៀត ។

- លោកពូ បានបញ្ជាក់ហើយបញ្ជាក់ទៀតថា គាត់ចង់ឃើញភូមិរបស់គាត់មានប្រាក់សន្សំច្រើន ដែលការសន្សំនេះកើតចេញពីប្រជាកសិករ ជៀសវាងពេលខ្វះខាតរត់រកគេនាំតែពិបាក កាលណាប្រជាកសិករយើងភ្ញាក់រលឹកក្នុងការសន្សំប្រាក់កាន់តែច្រើន ធ្វើឲ្យកសិករមានលុយខ្ចី កាន់តែច្រើន ធ្វើឲ្យកសិករជួយគ្នាបានកាន់តែច្រើន ។ គាត់មានជំនឿថា ប្រជាជនភូមិគាត់អាចធ្វើបាន ។ គាត់ប្តេជ្ញាថានឹងបង្កើនទុនសន្សំបន្ថែម ដោយសន្សំតាមលទ្ធភាពដែលរកបាន ជួយផ្សព្វផ្សាយដល់ប្រជាជន និងអ្នកដែលមិនទាន់បានចូលក្រុម ឲ្យយល់បន្ថែមទៀត ។ នៅចុងខែសីហានេះ គាត់នឹងសហការជាមួយគណៈកម្មការក្រុមរៀបចំប្រមូលចងក្រងប្រជាជន គាត់បង្កើតជាក្រុមសន្សំប្រាក់ឲ្យបានមួយក្រុមទៀត យ៉ាងហោចណាស់មានសមាជិក ១០ នាក់បន្ថែមទៀត ។

ឧទាហរណ៍ខាងលើនេះបញ្ជាក់ថា អាជ្ញាធរមូលដ្ឋានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយជម្រុញការងារមូលដ្ឋាន ជាពិសេសភូមិរបស់ខ្លួន ឲ្យកាន់តែប្រសើរមានមុខ មានមាត់ដោយចូលរួមចំណែកក្នុងការដាក់ប្រាក់សន្សំ បង្កើននូវភាពទុកចិត្តពីប្រជាជន ជួយផ្សព្វផ្សាយ ដាស់តឿន ក្រើនរំលឹកពន្យល់ឲ្យ យល់ពីការអភិវឌ្ឍន៍ដែលអាស្រ័យខ្លួនឯង ចូលរួមប្រជុំ និងជួយបង្កើនសមាជិកសន្សំ និងបង្កើនទុនសន្សំបន្ថែមទៀត ធានាថាអ្វីដែលប្រាថ្នាចង់បាននឹងមកដល់ក្នុងរយៈពេលដ៏ខ្លីខាងមុខ។

**ពេលវេលាជាលុយកាក់**

**យើងនាំគ្នាសន្សំ និងបង្កើនការសន្សំឱ្យបានគ្រប់ៗគ្នា**

**តាត់ សុខ**